**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះសីហនុ**
សំណុំរឿងរដ្ឋប្បវេណីលេខ ២០៤
ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២
សាលក្រមលេខ ១៥១/២២ (ជ)
ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០២២

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តព្រះសីហនុ**

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ដោយមានសមាសភាពជំនុំជម្រះមានដូចតទៅ

**<u>ចៅក្រម</u>**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

-បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខ ២០៤ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២ រវាង ៖

**-ដើមចោទ**

-ឈ្មោះ [redacted] សុខា ភេទប្រុស កើតឆ្នាំ១៩៦៩ មានអាសយដ្ឋាន [redacted]។

-ដោយមានលោក [redacted] មានការិយាល័យឈ្មោះ [redacted] ស្ថិតនៅកែ [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

**-សហចុងចម្លើយ**

១.ឈ្មោះ [redacted] ជុំ ភេទប្រុស អាយុ៥១ឆ្នាំ មានទីលំនៅបច្ចុប្បន្ន [redacted]

-ដោយមានលោកស្រី [redacted] មានការិយាល័យនៅ [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

២.ឈ្មោះ [redacted] សំ ភេទប្រុស អាយុ៤៣ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] សុគន្ធណា អាយុ៤០ឆ្នាំ មានទីលំនៅបច្ចុប្បន្ន[redacted]។

## ១.អង្គហេតុ និងចំណុចទទាន

### ១.១.សាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញរួមមាន៖

ក-ប្តឹងលុបត្រង់ចំណុចទី១.ខ ចំពោះវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៨០១០៣០២២-០០៩២ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តព្រះសីហនុ នៃដីកាសម្រេចរក្សាការពារលេខ ៥២ តរ១២ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តព្រះសីហនុ ។

ខ-សុំឲ្យតុលាការ អនុវត្តជាបណ្តោះអាសន្ន ។

គ-សុំទាមទារជំងឺចិត្ត និងការខាតបង់ទៅលើការចំណាយផ្សេងៗ ដោយសារសហចុងចម្លើយធ្វើឲ្យយឺតយ៉ាវក្នុងការខ្ចីប្រាក់ពីធនាគារចំនួន ១៦ ០០០ ០០០(ដប់ប្រាំមួយលាន) រៀល។

ឃ-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

### ១.២.ការពន្យល់ត្រួសៗអំពីរឿងក្តី

តាមពាក្យបណ្តឹង ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ របស់ដើមចោទឈ្មោះ [redacted] សុខា បានអះអាងថា សាលាដំបូងខេត្តព្រះសីហនុ បានចេញដីកាសម្រេចរក្សាការពារលេខ ៥២ ត.រ១២ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ ដោយបានសម្រេចហាមឃាត់ឈ្មោះ [redacted] សំ ភេទប្រុស អាយុ៤៣ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] សុគន្ធណា អាយុ៤០ឆ្នាំ មិនឲ្យធ្វើការលក់ ដូរ បញ្ចាំ ផ្ទេរ ជួល ធ្វើអំណោយ អច្ច័យទាន ធ្វើការផ្លាស់ប្តូរស្ថានភាពបច្ចុប្បន្ននៃផ្ទះ និងដី ដូចខាងក្រោម៖ ក.ផ្ទះ និងដី ដែលមានទីតាំងស្ថិតនៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលមានក្បាលដីលេខ ៩៨ (វិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៨០១០៣០២២-០០៩៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់

និងសុរិយោដីខេត្តព្រះសីហនុ ខ.ផ្ទះ និងដី ដែលមានទីតាំងស្ថិតនៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៨០១០៣០២២-០០៩២ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ គ.ដីទំហំទទឹង ៨ម៉ែត្រ គុណ ២០ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ឈ្មោះ [redacted] សម្ការ ខាងត្បូងទល់ឈ្មោះ [redacted] សំណាង ខាងកើតទល់ផ្លូវ និងខាងលិចទល់នឹងរបងថ្ម មានទីតាំងស្ថិតនៅសង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ជាបណ្ដោះអាសន្ន រង់ចាំតុលាការសម្រេចដល់អង្គសេចក្ដី សេចក្ដីសម្រេចត្រង់ចំណុចទី២(ចំណុចៈខ) នៃដីកាសម្រេចលើ ផ្ទះ និងដី ដែលមានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៨០១០៣០២២-០០៩២ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ បានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួនយ៉ាងធ្ងន់ធ្ងរ ។ ខ្លួនជាម្ចាស់កម្មសិទ្ធិស្របច្បាប់លើផ្ទះ និងដី ដែលមានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៨០១០៣០២២-០០៩២ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ ។ ខ្លួន និងម្ចាស់បំណុលឈ្មោះ [redacted] ផ្ទុំ មិនទំនាក់ទំនងគតិយុត្តិ ឬកិច្ចសន្យា ឬសិទ្ធិលើបំណុលណាមួយលើទ្រព្យ និងជាមួយកូនបំណុលឈ្មោះ អ៊ុំ សំក៏ដូចគ្នាដែរ គឺ មិនទំនាក់ទំនងគតិយុត្តិ ឬយកផ្ទះ និងដីរបស់ខ្លួន ដើម្បីដាក់ធានាលើបំណុល ។

## ១.៣.សេចក្ដីថ្លែងការណ៍របស់គូភាគី

**-សេចក្ដីថ្លែងការណ៍របស់ដើមចោទៈ** ខ្ញុំជាអ្នកតំណាងដោយអាណត្តិឲ្យភាគីដើមចោទ សូមធ្វើសេចក្ដីថ្លែងការណ៍ដូចតទៅៈ ខ្ញុំបាទសូមរក្សារាល់ខ្លឹមសារដូចមាននៅក្នុង ពាក្យបណ្ដឹងតវ៉ាដោយតតិយជន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ របស់ដើមចោទឈ្មោះ [redacted] សុខា ទុកជាបានការដដែល។ គ្រាន់តែសូមបញ្ជាក់បន្ថែមថា ចំពោះអចលនវត្ថុដែលមានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៨០១០៣០២២-០០៩២ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ ពិតជាកម្មសិទ្ធិរបស់កូនក្ដីរបស់ខ្ញុំបាទប្រាកដមែន ។ បើតាមការពិនិត្យអង្គហេតុ គឺភាគីខាងសហចុងចម្លើយមានវិវាទជាមួយនឹងគ្នា ដោយពុំមានពាក់ព័ន្ធជាមួយកូនក្ដីរបស់ខ្ញុំបាទនោះទេ ហើយតុលាការបានសម្រេចរក្សាការពារលើអចលនវត្ថុរបស់កូនក្ដីខ្ញុំបាទ ។ ដូច្នេះកូនក្ដី

របស់ខ្ញុំបាទ ពុំមានទំនាក់ទំនងគតិយុត្តិ ដែលតម្រូវឲ្យរក្សាការពារលើអចលនវត្ថុរបស់កូនក្តី ខ្ញុំបាទឡើយ ហេតុដូចនេះដើម្បីជៀសវាងប៉ះពាល់ដល់ផលប្រយោជន៍ធ្ងន់ធ្ងរ និងដើម្បីឲ្យកូនក្តីរបស់ខ្ញុំបាទ មានសិទ្ធិពេញលេញលើអចលនវត្ថុរបស់ខ្លួន ដែលជាម្ចាស់កម្មសិទ្ធិករស្របច្បាប់ សូមតុលាការ ចេញដីកាលុប លុបត្រង់ចំណុចទី១.ខ ចំពោះវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ លេខ ១៨០១០៣០២២-០០៩២ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ នៃដីកាសម្រេចរក្សាការពារលេខ ៥៤ តរ១២ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តព្រះសីហនុ និងសូមថ្លែងការណ៍តបរបស់មេធាវីចុងចម្លើយឈ្មោះ [redacted] ភ្នុំ ថា មូលហេតុដែលកូនក្តីខ្ញុំបាទទាមទារជំងឺចិត្ត និងការខាតបង់ ព្រោះកូនក្តីខ្ញុំបាទបាន បង់ពន្ធ និងចំណាយផ្សេងៗ តាមនីតិវិធីច្បាប់ និងធ្វើឲ្យយឺតយ៉ាវក្នុងការខ្ចីប្រាក់ពីធនាគារដែលខាតទៅលើការប្រាក់ផងដែរ។

**-សេចក្តីថ្លែងការណ៍របស់ចុងចម្លើយៈ** ខ្ញុំបាទជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ សូមរក្សាសេចក្តីថ្លែងការណ៍ ដូចមានក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ទុកជាបានការដដែល និងសូមធ្វើការបញ្ជាក់បន្ថែមថា កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ ឈ្មោះ [redacted] សំ បានខ្ចីប្រាក់កូនក្តីយើងខ្ញុំឈ្មោះ [redacted] ផ្ទុំ មានទឹកប្រាក់សរុប **៥៤០០០ (ប្រាំមុឺនបួនពាន់) ដុល្លារអាមេរិក** ដោយភ្ជាប់ការប្រាក់ ៧% ក្នុងមួយខែ ប៉ុន្តែចាប់ពីថ្ងៃខ្ចីប្រាក់ខាងលើមក ឈ្មោះ [redacted] សំ ពុំបានអនុវត្តកាតព្វកិច្ចសងប្រាក់ខាងលើឲ្យមកកូនក្តីយើងខ្ញុំឡើយ រហូតដល់ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១២ ក្រោយពីទទួលបានការណែនាំពីមេធាវី កូនក្តីយើងខ្ញុំក៏បានដាក់ពាក្យសុំរក្សាការពារលើផ្ទះ និងដី ដែលជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] សំ ខាងក្រោមនេះតែម្តងទៅ៖

- ផ្ទះ និង ដី ដែលមានទីតាំងស្ថិតនៅ ភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលមានក្បាលដីលេខ ៩៨ (វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០០៩៨)។
- ផ្ទះ និង ដី ដែលមានទីតាំងស្ថិតនៅ ភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលមានក្បាលដីលេខ ៩២ (វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០០៩២)។



Scanned with CamScanner

– ដីទំហំទទឹង ៨ ម៉ែត្រ គុណនឹងបណ្តោយ ២០ ម៉ែត្រ ព្រំប្រទល់ខាងជើងទល់ឈ្មោះ [redacted] សម្ភារ ខាងត្បូងទល់ឈ្មោះ [redacted] សំណាង ខាងកើតទល់ផ្លូវ និងខាងលិចទល់នឹងរបងថ្ម ដែលមានទីតាំងស្ថិតនៅ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

លុះដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ សាលាដំបូងខេត្តព្រះសីហនុ ក៏បានរក្សាការពារដីទាំង ០៣ កន្លែងខាងលើ តាមរយៈដីកាសម្រេចរក្សាការពារលេខ ៥៤ ត.រ/១២ តែម្តង ។ ប៉ុន្តែក្រោយមក នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ ក៏ស្រាប់តែមានពាក្យបណ្តឹងតវ៉ាដោយតតិយជនឈ្មោះ [redacted] សុខា លើដីដែលបានរក្សាការពារ ០១ កន្លែង ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០០៩២ (ត្រង់ចំណុច ខ នៃសេចក្តីសម្រេចរក្សាការពារ) ទើបកូនក្តីយើងខ្ញុំដឹងថា ដីនេះពុំមែនជារបស់ឈ្មោះ [redacted]សំ នោះទេ ។ តាមពាក្យបណ្តឹងតវ៉ាដោយតតិយជន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ ភាគីដើមចោទបានប្តឹងសុំលុបត្រង់ចំណុច (ខ) ចំពោះវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៨០១០៣០២២-០០៩២ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តព្រះសីហនុ នៃដីកាសម្រេចរក្សាការពារលេខ ៥៤ តរ/១២ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តព្រះសីហនុ ។ ចំពោះការទាមទារនេះ យើងខ្ញុំឯកភាពតាមការស្នើសុំរបស់ភាគីដើមចោទ និងស្នើសុំឲ្យតុលាការមេត្តាលុបចោល ចំណុច (ខ) នៃសេចក្តីសម្រេចបញ្ចប់ នៃដីកាសម្រេចរក្សាការពារលេខ ៥៤ ត.រ/១២ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ ស្តីអំពីការរក្សាការពារលើផ្ទះ និង ដីដែលមានទីតាំងស្ថិតនៅ ភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលមានក្បាលដីលេខ ៩២ (វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០០៩២)ដោយហេតុថា ការរក្សាការពារលើដីខាងលើនេះ គឺជាការកាន់ច្រឡំ ដែលកូនក្តីយើងខ្ញុំពុំបានដឹងថា ដីនេះជាកម្មសិទ្ធិស្របច្បាប់របស់ឈ្មោះ [redacted] សុខាឡើយ ។ បន្ថែមពីនេះ ចំពោះការទាមទារជំងឺចិត្ត និងការខាតបង់ទៅលើការចំណាយផ្សេងៗ ដោយសារចុងចម្លើយធ្វើឱ្យយឺតយ៉ាវក្នុងការខ្ចីប្រាក់ពីធនាគារចំនួនទឹកប្រាក់ **១៦,០០០,០០០ (ដប់ប្រាំមួយលាន)រៀល** នោះ គឺយើងខ្ញុំសុំច្រានចោលទាំងស្រុង ដោយហេតុថា ភាគីដើមចោទ ពុំមានភស្តុតាងជាក់ស្តែងដើម្បីលើកយកមកធ្វើការបញ្ជាក់អំពីការខាតបង់ខាងលើនេះឡើយ ។ ម៉្យាងទៀត ក្រោយពីទទួលបានពាក្យបណ្តឹងខាងលើ កូនក្តីយើងខ្ញុំបានព្យាយាមទំនាក់ទំនងទៅភាគីដើមចោទឲ្យមកដោះស្រាយ និងសម្របសម្រួលគ្នា ប៉ុន្តែភាគីដើមចោទពុំបានចូលរួមសហការនោះទេ ទោះបីជាមានការដាស់តឿនជា

ច្រើនលើកច្រើនសាយ៉ាងណាក៏ដោយ ។ កូនក្តីយើងខ្ញុំពុំបាននាំឲ្យមានការខាតបង់ផលប្រយោជន៍របស់ភាគីដើមចោទឡើយ មានតែព្យាយាមចូលខ្លួនមកដោះស្រាយ ។ ដូច្នេះ ដើម្បីការពារផលប្រយោជន៍របស់កូនក្តីយើងខ្ញុំកុំឲ្យមានការខាតបង់ធ្ងន់ធ្ងរ ស្នើសុំឲ្យតុលាការមេត្តាច្រានចោលចំណុចទី៣ នៃពាក្យបណ្តឹងតវ៉ាដោយតតិយជន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២។

**១.៤.ចំណុចវិវាទ និង ចំណុចដែលគ្មានវិវាទ**

**-ចំណុចដែលគ្មានវិវាទ:** គូភាគីព្រមព្រៀងលុបរក្សាការពារ ដោយស្ម័គ្រចិត្ត។

**-ចំណុចវិវាទ:** តើដើមចោទអាចទាមទារសំណង់បានដែរឬទេ។

**<u>២.ផ្នែកសំអាងហេតុ</u>**

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងការពិនិត្យភស្តុតាង នៅក្នុងនីតិវិធីទាញសម្រាប់ ការទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា ៖

២.១.តាមពាក្យបណ្តឹង ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ របស់ដើមចោទឈ្មោះ [redacted] សុខា បានបញ្ជាក់ថា សាលាដំបូងខេត្តព្រះសីហនុ បានចេញដីកាសម្រេចរក្សាការពារលេខ ៥៤ ត.វ១២ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ ដោយបានសម្រេចហាមឃាត់ឈ្មោះ [redacted] សំភេទប្រុស អាយុ៤៣ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] សុគន្ធណា អាយុ៤០ឆ្នាំ មិនឲ្យធ្វើការលក់ ដូរ បញ្ចាំ ផ្ទេរ ជួល ធ្វើអំណោយ អច្ច័យទាន ធ្វើការផ្លាស់ប្តូរស្ថានភាពបច្ចុប្បន្ននៃផ្ទះ និងដី ដែលមានទីតាំងស្ថិតនៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៨០១០៣០២២-០០៩២ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ ជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តី បានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួនយ៉ាងធ្ងន់ធ្ងរ ។ ខ្លួនជាម្ចាស់កម្មសិទ្ធិស្របច្បាប់លើផ្ទះ និងដីនេះ ហើយខ្លួន និងម្ចាស់បំណុលឈ្មោះ [redacted] ផុំ មិនទំនាក់ទំនងគតិយុត្តិ ឬកិច្ចសន្យា ឬសិទ្ធិលើបំណុលណាមួយលើទ្រព្យនិងជាមួយកូនបំណុលឈ្មោះ [redacted] សំ ក៏ដូចគ្នាដែរ គឺ មិនទំនាក់ទំនងគតិយុត្តិ ឬយកផ្ទះ និងដីរបស់ខ្លួន ដើម្បីដាក់ជានាលើបំណុល។

**-តាមការអះអាងរបស់ដើមចោទ:** ចំពោះអចលនវត្ថុដែលមានវិញ្ញាបនបត្រសម្គាប់អចលនវត្ថុលេខ ១៨០១០៣០២២-០០៩២ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ ពិតជាកម្មសិទ្ធិរបស់កូនក្តីរបស់ខ្លួនប្រាកដមែន ។ បើតាមការពិនិត្យអង្គហេតុ គឺភាគីខាងសហចុងចម្លើយ

មានវិវាទជាមួយនឹងគ្នា ដោយពុំមានពាក់ព័ន្ធជាមួយកូនក្តីរបស់ខ្លួននោះទេ ហើយតុលាការបានសម្រេចរក្សាការពារលើអចលនវត្ថុរបស់កូនក្តីខ្លួន ដោយកូនក្តីខ្លួន ពុំមានទំនាក់ទំនងគតិយុត្តិ ដែលតម្រូវឲ្យរក្សាការពារលើអចលនវត្ថុរបស់កូនក្តីខ្លួនឡើយ ហេតុដូចនេះដើម្បីជៀសវាងប៉ះពាល់ដល់ផលប្រយោជន៍ធ្ងន់ធ្ងរ និងដើម្បីឲ្យកូនក្តីរបស់ខ្លួន មានសិទ្ធិពេញលេញលើអចលនវត្ថុរបស់ខ្លួន ដែលជាម្ចាស់កម្មសិទ្ធិករស្របច្បាប់ សូមតុលាការ ចេញដីកាលុបត្រង់ចំណុចទី១.ខ ចំពោះវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៨០១០៣០២២-០០៩២ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្តព្រះសីហនុ នៃដីកាសម្រេចរក្សាការពារលេខ ៥២ តរ១២ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តព្រះសីហនុ និងសូមថ្លៃងការណ៍តប របស់មេធាវីចុងចម្លើយឈ្មោះ [redacted] កុំ ថាមូលហេតុដែលកូនក្តីខ្លួនទាមទារជំងឺចិត្ត និងការខាតបង់ ព្រោះកូនក្តីខ្លួនបាន បង់ពន្ធ និងចំណាយផ្សេងៗ តាមនីតិវិធីច្បាប់ និងធ្វើឲ្យយឺតយ៉ាវក្នុងការខ្ចីប្រាក់ពីធនាគារដែលខាតទៅលើការប្រាក់ផងដែរ។

**-តាមការអះអាងរបស់សហចុងចម្លើយឈ្មោះ [redacted] សំ បានអះអាងថា:** ចំពោះវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៨០១០៣០២២-០០៩២ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ គឺមិនមែនជាកម្មសិទ្ធិរបស់ខ្លួនទេ ដូច្នេះសូមតុលាការ លុបរក្សាការពារនេះ ចោល តាមពាក្យបណ្តឹងរបស់ដើមចោទ ។

**-តាមការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យសហចុងចម្លើយឈ្មោះ [redacted] ផុំ បានអះអាងថា:** តាមពាក្យបណ្តឹងតវ៉ាដោយតតិយជន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ ភាគីដើមចោទបានប្តឹងសុំលុបត្រង់ចំណុច (ខ) ចំពោះវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៨០១០៣០២២-០០៩២ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តព្រះសីហនុ នៃដីកាសម្រេចរក្សាការពារលេខ ៥២ តរ/១២ ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តព្រះសីហនុ ។ ចំពោះការទាមទារនេះ ខ្លួនឯកភាពតាមការស្នើសុំរបស់ភាគីដើមចោទ និងស្នើសុំឲ្យតុលាការមេត្តាលុបចោល ចំណុច (ខ) នៃសេចក្តីសម្រេចបញ្ចប់ នៃដីកាសម្រេចរក្សាការពារលេខ ៥២ ត.រ/១២ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ ស្តីអំពីការរក្សាការពារលើផ្ទះ និង ដី ដែលមានទីតាំងស្ថិតនៅ ភូមិ២ សង្កាត់លេខ



Scanned with CamScanner

៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលមានក្បាលដីលេខ ៩២ (វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០០៩២) ដោយហេតុថា ការរក្សាការពារលើដីខាងលើនេះ គឺជាការកាន់ច្រឡំដែលកូនក្តីខ្លួនពុំបានដឹងថា ដីនេះជាកម្មសិទ្ធិស្របច្បាប់របស់ឈ្មោះ [redacted] សុខាឡើយ ។ចំពោះការទាមទារជំងឺចិត្ត និងការខាតបង់ទៅលើការចំណាយផ្សេងៗ ដោយសារចុងចម្លើយធ្វើឱ្យយឺតយ៉ាវក្នុងការខ្ចីប្រាក់ពីធនាគារចំនួនទឹកប្រាក់ **១៦,០០០,០០០ (ដប់ប្រាំមួយលាន) រៀល** នោះ គឺខ្លួនសុំច្រានចោលទាំងស្រុង ដោយហេតុថា ភាគីដើមចោទ ពុំមានភស្តុតាងជាក់ស្តែងដើម្បីលើកយកមកធ្វើការបញ្ជាក់អំពីការខាតបង់ខាងលើនេះឡើយ ។ ម៉្យាងទៀត ក្រោយពីទទួលបានពាក្យបណ្តឹងខាងលើ កូនក្តីយើងខ្លួនព្យាយាមទំនាក់ទំនងទៅភាគីដើមចោទឲ្យមកដោះស្រាយ និងសម្របសម្រួលគ្នា ប៉ុន្តែភាគីដើមចោទពុំបានចូលរួមសហការនោះទេ ទោះបីជាមានការដាស់តឿនជាច្រើនលើកច្រើនសាយ៉ាងណាក៏ដោយ ។ កូនក្តីខ្លួនពុំបាននាំឲ្យមានការខាតបង់ផលប្រយោជន៍របស់ភាគីដើមចោទឡើយ មានតែព្យាយាមចូលខ្លួនមកដោះស្រាយ ។ ដូច្នេះ ដើម្បីការពារផលប្រយោជន៍របស់កូនក្តីខ្លួនកុំឲ្យមានការខាតបង់ធ្ងន់ធ្ងរ ស្នើសុំឲ្យតុលាការមេត្តាច្រានចោល ចំណុចទី៣ នៃពាក្យបណ្តឹងតវ៉ាដោយតតិយជន ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ ។

**២.២.** ផ្អែកតាមការពិនិត្យភស្តុតាង:

-ដីកាសម្រេចរក្សាការពារលេខ៥៤ ត.រ១២ ចុះថ្ងៃទីទី១៦ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលមានម្ចាស់បំណុលឈ្មោះ [redacted] ផុំ ភេទប្រុស អាយុ៥១ឆ្នាំ ដែលបានសម្រេចហាមឃាត់ឈ្មោះ [redacted] សំ ភេទប្រុស អាយុ៤៣ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] សុគន្ធណា អាយុ៤០ឆ្នាំ មិនឲ្យធ្វើការលក់ ដូរ បញ្ចាំ ផ្ទេរ ជួល ធ្វើអំណោយ អច្ច័យទាន ធ្វើការផ្លាស់ប្តូរស្ថានភាពបច្ចុប្បន្ននៃផ្ទះ និងដី ដែលមានទីតាំងស្ថិតនៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៨០១០៣០២២-០០៩២ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ ជាបណ្តោះអាសន្ន ។

-លិខិតបញ្ជាក់ព័ត៌មានសុរិយោដីលេខ ៣៩៨ ជនសស/ខសន ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ របស់មន្ទីររៀបចំនដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ បានបញ្ជាក់ថា វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០៣០២-



Scanned with CamScanner

០០៩២ ស្ថិតនៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ទំហំ ២៤៧ម² រូបភាពប្រើប្រាស់ដី លំនៅដ្ឋាន របស់ឈ្មោះ [redacted] សុខា និងនាង [redacted] សារ៉េត មានចុះបញ្ជីតាមលិខិតផ្ទុកផ្តាក់ ហាមឃាត់ការចាត់ចែងជាបណ្តោះអាសន្ន តាមដីកាសម្រេចលេខ ៥៤ តរ/១២ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តព្រះសីហនុ ។

២.៣. តាមការពិនិត្យភស្តុតាងលើឯកសារ និងសេចក្តីថ្លែងការណ៍របស់គូភាគី តុលាការយល់ឃើញថា នៅក្នុងដីការក្សាការពារ ដែលបានហាមឃាត់ការចាត់ចែងជាបណ្តោះអាសន្ន នូវដី និងផ្ទះ គឺមិនមែនជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] សំ និងប្រពន្ធឈ្មោះ [redacted] សុគន្ធណា តែជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] សុខា និងឈ្មោះ [redacted] សារ៉េត ។ នៅក្នុងការទាញហេតុដោយផ្ទាល់មាត់ គូភាគីខាងសហចុងចម្លើយក៏បាន ឯកភាពគ្នា តាមទាមទាររបស់ដើមចោទ ដែលប្តឹងសុំលុបត្រង់ចំណុចទី១.ខ ចំពោះវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៨០១០៣០២២-០០៩២ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ នៃដីកាសម្រេចរក្សាការពារលេខ ៥៤ តរ១២ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តព្រះសីហនុ ដោយសារតែពេលនោះ សហចុងចម្លើយឈ្មោះ [redacted] ផ្ទុំ មានការភាន់ច្រឡំ ដោយមិនដឹងថា ដី និងផ្ទះ ជាកម្មសិទ្ធិរបស់ដើមចោទ ប៉ុន្តែចំពោះការទាមទារ ជំងឺចិត្ត និងការខាតបង់ទៅលើការចំណាយផ្សេងៗ ដោយសារចុងចម្លើយធ្វើឱ្យយឺតយ៉ាវក្នុងការខ្ចីប្រាក់ពីធនាគារ ចំនួនទឹកប្រាក់ **១៦,០០០,០០០ (ដប់ប្រាំមួយលាន) រៀល** នោះ នៅក្នុងសំណុំរឿង ពុំឃើញមានភាគីដើមចោទ បានដាក់ភស្តុតាងជាឯកសារ ឲ្យតុលាការ ពិនិត្យ ដើម្បីបញ្ជាក់អំពីការខាតបង់ឡើយ ។ ដូចនេះ គប្បីតុលាការ ពិចារណា ។

**២.៤.៧**-យោងតាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី(ការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន) ដូច្នេះការទាមទារឲ្យតុលាការអនុវត្តបណ្តោះអាសន្ន តុលាការអាចពិចារណាបានលើចំណុចទី ០២ នៃសេចក្តីសម្រេច ។

**២.៤.អំពីប្រាក់ប្រដាប់ក្តី**

-ចំពោះប្រាក់ប្រដាប់ក្តី ត្រូវអនុវត្តតាមមាត្រា៦២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**៣.ផ្នែកសម្រេចសេចក្តី**

**៣.១.** ទទួលស្គាល់ពាក្យបណ្តឹងតវ៉ាដោយតតិជន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ របស់ដើមចោទឈ្មោះ [redacted] សុខា ដោយសុំលុបត្រង់ចំណុចទី១.ខ ចំពោះវិញ្ញាបនបត្រសម្គាល់

អចលនវត្ថុលេខ ១៨០១០៣០២២-០០៩២ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ នៃដីកាសម្រេចរក្សាការពារលេខ ៥៤ តរ១២ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តព្រះសីហនុ ត្រឹមត្រូវតាមច្បាប់ ។

៣.២. លុបចោល ត្រង់ចំណុចទី១.ខ ចំពោះវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៨០១០៣០២២-០០៩២ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ នៃដីកាសម្រេចរក្សាការពារលេខ ៥៤ តរ១២ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តព្រះសីហនុ ។

៣.៣. បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] ផុំ និងឈ្មោះ [redacted] សំ រួមគ្នា សងសំណងរដ្ឋប្បវេណីដល់ដើមចោទឈ្មោះ [redacted] សុខា ជាទឹកប្រាក់ចំនួន ៨ ០០០ ០០០ (ប្រាំបីលាន) រៀល ។

៣.៤. សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នលើចំណុច ៣.២ នៃសេចក្តីសម្រេចបញ្ចប់ ទោះបីមានការប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក៏ដោយ ។

៣.៥. ប្រាក់ប្រដាក់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ចំពោះមុខដើមចោទ និងចុងចម្លើយ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ ។

ទុកសិទ្ធឲ្យគូភាគីប្តឹងឧបាស្រ័យតាមកំណត់ច្បាប់ ។

ថ្ងៃពុធ ១៥រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ព្រះសីហនុ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២

**ចៅក្រម**

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ខេត្តព្រះសីហនុ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]